ព្រឹត្តិបត្រព័ត៌មាន
គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប)
គ.ជ.ប NEC BULLETIN
លេខ ៤ ចេញផ្សាយថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០២៣
Issue 4 : 5 / 6 / 2023

# ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣

(ថ្ងៃអាទិត្យ ទី២៣ ខែកក្កដា ឆ្នាំ២០២៣)

## គ.ជ.ប រៀបចំកិច្ចប្រជុំផ្សព្វផ្សាយជាមួយភាគីពាក់ព័ន្ធស្តីពីការរៀបចំ និងការផលិតបណ្ណព័ត៌មានអ្នកបោះឆ្នោត សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣

នាព្រឹកថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២៣ នៅទីស្តីការគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) មានកិច្ចប្រជុំ





ឯកឧត្តម ឯម សុផាត សមាជិក គ.ជ.ប

តទៅទំព័រទី២

មាតិកា៖ ទំព័រ

- គ.ជ.ប រៀបចំកិច្ចប្រជុំផ្សព្វផ្សាយជាមួយភាគីពាក់ព័ន្ធស្តីពី ការរៀបចំ និងការផលិតបណ្ណព័ត៌មានអ្នកបោះឆ្នោត ..........១
- លទ្ធផលនៃការចាប់ឆ្នោត ដើម្បីកំណត់លំដាប់លេខរៀងឈ្មោះគណបក្សនយោបាយនៅលើសន្លឹកឆ្នោត ..................៤
- ក្រុមប្រតិកម្មព័ត៌មាន គ.ជ.ប បានចេញសេចក្តីបំភ្លឺពាក់ព័ន្ធនឹងការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ..៦
- គ.ជ.ប រៀបចំកម្មវិធីស្វែងយល់អំពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ តាមវិទ្យុ FM ........៧
- វគ្គបណ្តុះបណ្តាលគ្រូបង្គោល និងភ្នាក់ងារសន្តិសុខបោះឆ្នោត អំពីច្បាប់ស្តីពីការបោះឆ្នោត បទបញ្ជា និងនីតិវិធី ..........៩
- គ.ជ.ប ណែនាំអំពីកិច្ចសហការការងារសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ សម្រាប់ដំណើរការបោះឆ្នោត .១១
- ប្រធាន គ.ជ.ប ទទួលជួបឯកអគ្គរដ្ឋទូតអូស្ត្រាលី ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ..........................................១៣
- ខិត្តបណ្ណស្តីពី ការបោះឆ្នោតដោយសម្ងាត់ សេរី យុត្តិធម៌ និងតម្លាភាព ...........................................................១៦

តមកពីទំព័រទី១ **គ.ជ.ប រៀបចំកិច្ចប្រជុំ ...**

ជាមួយភាគីពាក់ព័ន្ធនឹងការបោះឆ្នោតក្រោមអធិបតីភាព ឯកឧត្តម **ឯម សូផាត** សមាជិក គ.ជ.ប និងជាប្រធានដឹកនាំកិច្ចប្រជុំ ដែលមានប្រធានបទស្តីពី ការរៀបចំ និងការផលិតបណ្ណព័ត៌មានអ្នកបោះឆ្នោត ការចែកបណ្ណព័ត៌មានអ្នកបោះឆ្នោត បច្ចុប្បន្នភាពចំនួនអ្នកសារព័ត៌មានជាតិ និងអន្តរជាតិ និងក្រមសីលធម៌សម្រាប់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានក្នុងដំណើរការបោះឆ្នោត។

ឯកឧត្តម **ឯម សូផាត** បានមានប្រសាសន៍ថា គោលបំណងនៃការផ្តល់បណ្ណព័ត៌មានអ្នកបោះឆ្នោតនេះ ទី១ គឺដើម្បីជួយផ្តល់ព័ត៌មានគ្រប់គ្រាន់ដល់អ្នកបោះឆ្នោតដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតផ្លូវការ បានយល់ដឹងអំពីកាលបរិច្ឆេទ និងពេលវេលានៃការបោះឆ្នោត លេខកូដ និងទីតាំងការិយាល័យ



តំណាងភាគីពាក់ព័ន្ធចូលរួមក្នុងកិច្ចប្រជុំ

បោះឆ្នោត លេខរៀង ឈ្មោះ និងទិន្នន័យរបស់អ្នកបោះឆ្នោតក្នុងបញ្ជីបោះឆ្នោត និងប្រភេទឯកសារបញ្ជាក់អត្តសញ្ញាណផ្លូវការដែលត្រូវប្រើនៅពេលបោះឆ្នោត ទី២ បង្កភាពងាយស្រួលដល់អ្នកបោះឆ្នោត ក្នុងការរកឃើញការិយាល័យបោះឆ្នោតដែលសាមីខ្លួនត្រូវបោះឆ្នោត និងទី៣ បង្កភាពងាយស្រួលដល់លេខាធិការនៃគណៈកម្មការការិយាល័យបោះឆ្នោត ក្នុងការរកឃើញឈ្មោះអ្នកបោះឆ្នោតភ្លាមៗ ដើម្បីឱ្យអ្នកបោះឆ្នោតអាចបោះឆ្នោតបានឆាប់រហ័ស។

ចំពោះរបៀបផលិត និងទម្រង់បណ្ណព័ត៌មានអ្នកបោះឆ្នោតនេះ ឯកឧត្តម **ឯម សូផាត** បានគូសបញ្ជាក់ថា បណ្ណព័ត៌មានអ្នកបោះឆ្នោត ត្រូវបានផលិតតាមលក្ខណៈបច្ចេកទេសកុំព្យូទ័រ ដោយការផ្ទេរឈ្មោះ និងទិន្នន័យមួយចំនួនរបស់អ្នក



គណៈអធិបតីក្នុងកិច្ចប្រជុំជាមួយភាគីពាក់ព័ន្ធ

បោះឆ្នោតពីបញ្ជីបោះឆ្នោតផ្លូវការនៃការិយាល័យបោះឆ្នោតពាក់ព័ន្ធ មានន័យថាឈ្មោះ រូបថត និងទិន្នន័យអ្នកបោះឆ្នោតនៅលើបញ្ជីបោះឆ្នោតផ្លូវការ និងនៅលើបណ្ណព័ត៌មានអ្នកបោះឆ្នោត គឺដូចគ្នាទាំងស្រុង។ ឯកឧត្តមបានបន្តថា បណ្ណនេះ ត្រូវបានបោះពុម្ពសងខាង ដោយនៅផ្នែកខាងមុខ បោះពុម្ពអក្សរពណ៌ខ្មៅលើផ្ទៃក្រដាសពណ៌ស។ ចំណែកផ្នែកខាងខ្នងវិញ បោះពុម្ពអក្សរពណ៌ក្រហមលើផ្ទៃក្រដាសពណ៌ផ្ទៃមេឃខ្ចី ដើម្បីកុំឱ្យមានការភាន់ច្រឡំជាមួយនឹងបណ្ណព័ត៌មានអ្នកបោះឆ្នោតលើកមុនៗ។ ហើយនៅក្នុងឆ្នាំនេះ ចំនួនបណ្ណព័ត៌មានអ្នកបោះឆ្នោត ដែល គ.ជ.ប ត្រូវបោះពុម្ព គឺស្មើនឹងចំនួនអ្នកបោះឆ្នោតដែលមានក្នុងបញ្ជីបោះឆ្នោតផ្លូវការ ឆ្នាំ២០២២ ដែលនឹងត្រូវប្រើសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ ដែលមានចំនួនសរុប **៩.៧១០.៦៥៥** សន្លឹក។

ឯកឧត្តម **ឯម សូផាត** បានប្រៀបធៀបថា បណ្ណព័ត៌មានអ្នកបោះឆ្នោត ឆ្នាំ២០២៣ មានលក្ខណៈខុសប្លែកពីឆ្នាំមុនៗ ដោយ គ.ជ.ប បានបញ្ចូលបន្ថែមរូបថតសាមីអ្នកបោះឆ្នោតទៅ



តំណាងភាគីពាក់ព័ន្ធចូលរួមក្នុងកិច្ចប្រជុំ

ក្នុងផ្នែកខាងមុខនៃបណ្ណ ដើម្បីងាយស្រួលក្នុងការត្រួតពិនិត្យផ្ទៀងផ្ទាត់អត្តសញ្ញាណរបស់អ្នកបោះឆ្នោត។

ឯកឧត្តម **ឯម សូផាត** បានបញ្ជាក់ទៀតថា បណ្ណព័ត៌មានអ្នកបោះឆ្នោតនេះមិនអាចប្រើជំនួសអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ (អ.ខ) ដែលមានសុពលភាព ឬឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការបោះឆ្នោត (ឯ.អ) ក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ បានឡើយ។

អំពីការចែកបណ្ណព័ត៌មានអ្នកបោះឆ្នោត ឯកឧត្តម **ឯម សូផាត** លើកឡើងថា ផ្អែកតាមសេចក្តីសម្រេចលេខ ១២៥ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២៣ ស្តីពីការផលិត និងការចែកបណ្ណព័ត៌មានអ្នកបោះឆ្នោត បានតម្រូវឱ្យគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត (គឃ.សប) ចាត់តាំងក្រុមចែកបណ្ណព័ត៌មានអ្នកបោះឆ្នោតមួយ ឬច្រើនក្រុម ឱ្យសមស្របតាមចំនួនភូមិ និងទៅតាមភូមិសាស្ត្រជាក់ស្តែងក្នុងឃុំ សង្កាត់របស់ខ្លួន និងត្រូវមានសមាសភាព៖

- សមាជិកគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត ១រូប ជាប្រធាន
- សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ១រូប ឬច្រើនរូប ជាសមាជិក
- តំណាងសមាគម ឬអង្គការមិនមែនរដ្ឋាភិបាល ១រូប ឬច្រើនរូប (ប្រសិនបើមាន) ជាសមាជិក
- និងមេភូមិ ឬជំនួយការភូមិពាក់ព័ន្ធ ជាសមាជិក

ចំពោះអវត្តមានរបស់តំណាងសមាគម ឬអង្គការមិនមែនរដ្ឋាភិបាល ក្នុងក្រុមចែកបណ្ណព័ត៌មាន មិនអាចធ្វើឱ្យរាំងស្ទះ



តំណាងភាគីពាក់ព័ន្ធមានសំណួរក្នុងកិច្ចប្រជុំ



សកម្មភាពក្នុងកិច្ចប្រជុំជាមួយភាគីពាក់ព័ន្ធ

ដល់ដំណើរការចែកបណ្ណព័ត៌មានអ្នកបោះឆ្នោតឡើយ។ រីឯគណបក្សនយោបាយ និងសមាគម ឬអង្គការមិនមែនរដ្ឋាភិបាល ដែលមិនមែនជាសមាជិកក្រុមចែកបណ្ណព័ត៌មាន អាចបញ្ជូនតំណាងរបស់ខ្លួនឱ្យតាមសង្កេតមើលដំណើរការនៃការចែកបណ្ណព័ត៌មានក្នុងឃុំ សង្កាត់ពាក់ព័ន្ធបាន។

អំពីកាលបរិច្ឆេទនៃការចែកបណ្ណព័ត៌មានអ្នកបោះឆ្នោត ឯកឧត្តម **ឯម សូផាត** បានជម្រាបជូនថា ចែកជូនប្រជាពលរដ្ឋតាមភូមិនានាក្នុងឃុំ សង្កាត់ ចាប់ផ្តើមពីថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២៣ រហូតដល់ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២៣។ ចំពោះបណ្ណដែលនៅសល់ នៅតែបន្តចែកនៅទីស្នាក់ការគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត (គឃ.សប) ដែលតម្រូវឱ្យប្រជាពលរដ្ឋត្រូវទៅទទួលបណ្ណព័ត៌មានអ្នកបោះឆ្នោតដោយខ្លួនឯង ចាប់ពីថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២៣ រហូតដល់ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២៣។

ពាក់ព័ន្ធនឹងការចេញបណ្ណសម្គាល់ខ្លួនជាអ្នកសារព័ត៌មាន ឯកឧត្តម **ឯម សូផាត** បានមានប្រសាសន៍ថា គិតត្រឹមថ្ងៃទី២២ ខែឧសភា ឆ្នាំ២០២៣ នេះ គ.ជ.ប បានចេញបណ្ណសម្គាល់ខ្លួនជាផ្លូវការជូនអ្នកសារព័ត៌មានជាតិ ចំនួន ២២០នាក់ (ស្រី២៣នាក់) មកពី ២១ អង្គភាព និងអ្នកសារព័ត៌មានអន្តរជាតិ ចំនួន ៣០នាក់ (ស្រី ២នាក់) មកពី ១៤ អង្គភាព។

ក្នុងកិច្ចប្រជុំនោះ ឯកឧត្តម **ឯម សូផាត** ក៏បានលើកឡើងផងដែរអំពីក្រមសីលធម៌សម្រាប់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ក្នុងដំណើរការបោះឆ្នោតដែលរួមមាន អំពីសិទ្ធិរបស់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ការទទួលខុសត្រូវ និងកាតព្វកិច្ចរបស់ប្រព័ន្ធផ្សព្វ-



តំណាងភាគីពាក់ព័ន្ធមានសំណួរក្នុងកិច្ចប្រជុំ

ផ្សាយព័ត៌មាន និងបម្រាមចំពោះប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ដែលត្រូវបានហាមឃាត់មានដូចជា ការផ្សាយព័ត៌មានដែលធ្វើឱ្យមានការភាន់ច្រឡំ នាំឱ្យបាត់ទំនុកចិត្តលើការបោះឆ្នោត ការបន្លំឱ្យគេយល់ខុសដូចជា ការសរសេរបញ្ចិតបញ្ចៀងដើម្បីឱ្យសាធារណជនមានការសង្ស័យ ដោយអយុត្តិធម៌លើបុគ្គលណាម្នាក់ ឬ/និងក្រុមបក្សណាមួយ ។ល។

ឆ្លើយទៅនឹងសំណួររបស់ភាគីចូលរួមក្នុងកិច្ចប្រជុំពាក់ព័ន្ធនឹងឯកសារប្រើសម្រាប់បោះឆ្នោត គ.ជ.ប បានបញ្ជាក់ជូនថា គឺអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរដែលមានសុពលភាព ប្រើសម្រាប់បោះឆ្នោត នៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២៣។ ប្រសិនបើបាត់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ សូមអញ្ជើញទៅធ្វើឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការបោះឆ្នោត ទើបអាចបោះឆ្នោតបាន។ ការធ្វើឯកសារនេះត្រូវធ្វើក្នុងរយៈពេល ៣០ថ្ងៃ មុនថ្ងៃបោះឆ្នោត គឺចាប់ពីថ្ងៃទី២២ ខែមិថុនា ដល់ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២៣ នៅគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត (គឃ.សប) និងបន្ទាប់មកយកទៅជួបមេឃុំ ចៅសង្កាត់ ដើម្បីចុះហត្ថលេខា និងបោះត្រាផ្តល់សុពលភាពទើបអាចប្រើសម្រាប់បោះឆ្នោតបាន។

ជាចុងក្រោយ ឯកឧត្តម **ឯម សូផាត** បានអំពាវនាវចំពោះគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ គណបក្សនយោបាយឈរឈ្មោះបោះឆ្នោត សមាគម អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន និងភាគីពាក់ព័ន្ធទាំងអស់ចូលរួមគោរពច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ បទបញ្ជា និងនីតិវិធី ក្រមសីលធម៌ និងអនុវត្តតាមសេចក្តីណែនាំរបស់ គ.ជ.ប និងតាមតួនាទីភារកិច្ចរបស់ខ្លួនដើម្បីធានាឱ្យដំណើរការចែកបណ្ណព័ត៌មានអ្នកបោះឆ្នោត សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ នេះ ប្រព្រឹត្តទៅដោយរលូនល្អ ត្រឹមត្រូវ យុត្តិធម៌ និងមានតម្លាភាព។

ភាគីពាក់ព័ន្ធដែលចូលរួមក្នុងកិច្ចប្រជុំផ្សព្វផ្សាយដែលរៀបចំឡើងដោយ គ.ជ.ប រួមមានតំណាងមកពីអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា អគ្គលេខាធិការដ្ឋានរដ្ឋសភា ក្រសួងមហាផ្ទៃ ក្រសួងការពារជាតិ ក្រសួងព័ត៌មាន បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស អគ្គស្នងការដ្ឋាននគរបាលជាតិ ក្រុមប្រឹក្សាសកម្មភាពជនពិការ មន្ត្រីមកពីស្ថានទូតជប៉ុន តំណាងគណបក្សនយោបាយ តំណាងអង្គការមិនមែនរដ្ឋាភិបាល សមាគម និងអ្នកសារព័ត៌មាន ប្រមាណ ៦០ នាក់៕

# លទ្ធផលនៃការចាប់ឆ្នោត ដើម្បីកំណត់លំដាប់លេខរៀងឈ្មោះគណបក្សនយោបាយនៅលើសន្លឹកឆ្នោត សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣

ផ្អែកតាមលទ្ធផលនៃការចាប់ឆ្នោត ដើម្បីកំណត់លំដាប់លេខរៀងឈ្មោះគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតនៅលើសន្លឹកឆ្នោត សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ ដែលត្រូវបានធ្វើឡើងនៅទីស្តីការ គ.ជ.ប នៅព្រឹកថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២៣ គណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ទាំង ១៨ គណបក្ស ទទួលបាន

លំដាប់លេខរៀង ដូចខាងក្រោម៖

| លំដាប់លេខរៀង | ឈ្មោះគណបក្សនយោបាយ | លំដាប់លេខរៀង | ឈ្មោះគណបក្សនយោបាយ |
|---|---|---|---|
| ១ | គណបក្សសំបុកឃ្មុំសង្គមប្រជាធិបតេយ្យ | ១០ | គណបក្សធម្មាធិបតេយ្យ |
| ២ | គណបក្សខ្មែររួបរួមជាតិ | ១១ | គណបក្សប្រជាធិបតេយ្យមូលដ្ឋាន |
| ៣ | គណបក្សសញ្ញាតិកម្ពុជា | ១២ | គណបក្សបំណងពលរដ្ឋ |
| ៤ | គណបក្សខ្មែររួបរួមជាតិ | ១៣ | គណបក្សខ្មែរអភិវឌ្ឍន៍សេដ្ឋកិច្ច |
| ៥ | គណបក្សកម្លាំងប្រជាធិបតេយ្យ | ១៤ | គណបក្សឯកភាពជាតិខ្មែរ |
| ៦ | គណបក្សកសិករ | ១៥ | គណបក្សខ្មែរអភិរក្ស |
| ៧ | គណបក្សស្ត្រីដើម្បីស្ត្រី | ១៦ | គណបក្សយុវជនកម្ពុជា |
| ៨ | គណបក្សខ្មែរឈប់ក្រ | ១៧ | គណបក្សជនជាតិដើមប្រជាធិបតេយ្យកម្ពុជា |
| ៩ | គណបក្សហ៊្វុនស៊ិនប៉ិច | ១៨ | គណបក្សប្រជាជនកម្ពុជា |




**សកម្មភាពក្នុងពិធីចាប់ឆ្នោតដើម្បីកំណត់លំដាប់លេខរៀងឈ្មោះគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត**

សូមជម្រាបជូនថា ការប្រព្រឹត្តទៅនៃការចាប់ឆ្នោត ដើម្បីកំណត់លំដាប់លេខរៀងឈ្មោះគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតនៅលើសន្លឹកឆ្នោត បានធ្វើឡើងជាសាធារណៈ និងមានលំដាប់លំដោយ តាមការកំណត់ក្នុងបទបញ្ញា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣។ ក្នុងនោះ **សម្តេចព្រះអគ្គមហាសង្ឃរាជទាំងពីរគណៈ** បាននិមន្តយាងព្រះរាជប្រទានចាប់ឆ្នោត នៅចំពោះមុខ ឯកឧត្តមប្រធាន អនុប្រធាន និងសមាជិក គ.ជ.ប តំណាងគណបក្សនយោបាយ ទាំង ១៨ គណបក្ស តំណាងក្រសួង ស្ថាប័នជាតិពាក់ព័ន្ធ មន្ត្រីអគ្គលេខាធិការដ្ឋាន គ.ជ.ប តំណាងសមាគម និងអង្គការមិនមែនរដ្ឋាភិបាល និងអ្នកសារព័ត៌មានជាតិ-អន្តរជាតិជាច្រើន។



**សកម្មភាពក្នុងពិធីចាប់ឆ្នោតដើម្បីកំណត់លំដាប់លេខរៀងឈ្មោះគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត**

# ក្រុមប្រតិកម្មព័ត៌មាន គ.ជ.ប បានចេញសេចក្ដីបំភ្លឺពាក់ព័ន្ធនឹងការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ

បន្ទាប់ពីមានការលើកឡើងរបស់លោក **កន សាវ៉ាង្ស** អ្នកសម្របសម្រួលផ្នែកអង្កេត និងតស៊ូមតិ នៃអង្គការខុមហ្វ្រែល ថា "***ច្បាប់បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ មិនបានកំណត់ថា គណបក្សត្រូវយកឯកសារដើមទៅចុះឈ្មោះឡើយ***" និងសំណួររបស់លោក **ជួប នរក្សា** អ្នកសារព័ត៌មាននៃវិទ្យុបារាំងអន្តរជាតិ RFI ថា "***ការផ្លាស់ប្ដូរនីតិវិធីរបស់ គ.ជ.ប***" ក្នុងកិច្ចសម្ភាសន៍កាលពីថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២៣ ដែលអាចធ្វើឱ្យមានការភាន់ច្រឡំ បាត់ទំនុកចិត្ត និងមិនឆ្លុះបញ្ចាំងពីស្មារតីនៃការអនុវត្តការងារតាមផ្លូវច្បាប់របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) ក្នុងដំណាក់កាលចុះបញ្ជីគណបក្សនយោបាយឈរ-ឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើស-តាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ ក្រុមប្រតិកម្ម-ព័ត៌មាន គ.ជ.ប នៅថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០២៣ បានចេញសេចក្ដីបំភ្លឺជូនសាធារណជនអំពីការអនុវត្តកិច្ចការពាក់ព័ន្ធនឹងការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតនេះ។

ក្នុងសេចក្ដីបំភ្លឺនោះ ក្រុមប្រតិកម្មព័ត៌មាន គ.ជ.ប បានឱ្យដឹងថា គ.ជ.ប មិនបានកែប្រែនីតិវិធីរបស់ខ្លួនទេ ហើយឯកសារដើមដែល គ.ជ.ប តម្រូវក្នុងការដាក់ពាក្យចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ គឺមានដូចយោងក្នុងច្បាប់ ការណែនាំរបស់ក្រសួងមហាផ្ទៃ និង គ.ជ.ប។

ក្រុមប្រតិកម្មព័ត៌មាន គ.ជ.ប បានធ្វើការពន្យល់ដូចខាងក្រោម៖

- កថាខណ្ឌទី២ នៃមាត្រា ២៧ នៃច្បាប់ស្ដីពីការបោះ-ឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ចែងថា "***ដើម្បីចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតជ្រើស-តាំងតំណាងរាស្ត្រជាផ្លូវការ គណបក្សនយោបាយត្រូវធ្វើពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត តាមបែបបទកំណត់ដោយ គ.ជ.ប មក គ.ជ.ប យ៉ាងយូរ ៧០ (ចិតសិប)ថ្ងៃ មុនថ្ងៃបោះឆ្នោត ដោយភ្ជាប់មកជាមួយនូវឯកសារចំនួន ១០ ប្រភេទ ដែលប្រភេទទី១. សេចក្ដីចម្លងលិខិតបញ្ជាក់ការចុះ-បញ្ជីគណបក្សនយោបាយនៅក្រសួងមហាផ្ទៃ ១ ច្បាប់ និងប្រភេទទី២ ...***"។
- ផ្អែកតាមលិខិតក្រសួងមហាផ្ទៃលេខ ៨៩៥ សជណ ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២៣ ត្រេទី១ និងត្រេទី២ បានធ្វើការណែនាំដល់អង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្ត និងអភិបាលក្រុង ស្រុក ខណ្ឌ ក្នុងការជួយសម្របសម្រួលធ្វើនីត្យានុកូលកម្មលើប្រកាស ស្ដីពីការចុះបញ្ជីគណបក្សនយោបាយនៅក្រសួងមហាផ្ទៃ ដោយមិនគិតកម្រៃសេវា ដោយជួយសម្របសម្រួល និងបង្កលក្ខណៈងាយស្រួលក្នុងការចេញលិខិតបញ្ជាក់ផ្សេងៗ ជូនបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ របស់គណបក្សនយោបាយដែលបានចុះបញ្ជីត្រឹមត្រូវតាមច្បាប់ សម្រាប់យកទៅប្រើប្រាស់ក្នុងការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ ស្របតាមច្បាប់ស្ដីពីការបោះឆ្នោត និងបទបញ្ជា និងនីតិវិធី សម្រាប់ការបោះ-ឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧។
- ផ្អែកតាមសេចក្ដីជូនដំណឹងរបស់ គ.ជ.ប លេខ ០២៧ គ.ជ.ប.ស.ជ.ណ ចុះថ្ងៃទី៥ ខែមេសា ឆ្នាំ២០២៣ ស្ដីពីការរៀបចំបែបបទសម្រាប់ការចុះបញ្ជីគណបក្ស

នយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ ត្រង់ចំណុចទី១ បានកំណត់ថា "***គណបក្សនយោបាយត្រូវភ្ជាប់សេចក្តីចម្លងលិខិតបញ្ជាក់ការចុះបញ្ជីគណបក្សនយោបាយនៅក្រសួងមហាផ្ទៃ ដែលមានបញ្ជាក់នីត្យានុកូលកម្ម ដោយរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ***"។

- ផ្អែកតាមសេចក្តីជូនដំណឹងលេខ ០៤៤ គ.ជ.ប.ស.ជ.ណ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៨ ពីការរៀបចំបែបបទសម្រាប់ការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៦ ឆ្នាំ-២០១៨ ត្រង់ចំណុចទី១ បានកំណត់ថា "***គណបក្សនយោបាយត្រូវភ្ជាប់សេចក្តីចម្លងលិខិតបញ្ជាក់ការចុះបញ្ជីគណបក្សនយោបាយនៅក្រសួងមហាផ្ទៃ ដែលមានបញ្ជាក់នីត្យានុកូលកម្ម ដោយអាជ្ញាធរក្រុង ស្រុក ខណ្ឌ***"។

ក្រុមប្រតិកម្មព័ត៌មាន គ.ជ.ប បានបញ្ជាក់ទៀតថា សេចក្តីចម្លងលិខិតបញ្ជាក់ការចុះបញ្ជីគណបក្សនយោបាយនៅក្រសួងមហាផ្ទៃដែល គ.ជ.ប តម្រូវក្នុងការដាក់ពាក្យ គឺសំដៅទៅលើប្រកាសស្តីពីការចុះឈ្មោះក្នុងបញ្ជីគណបក្សនយោបាយនៅក្រសួងមហាផ្ទៃ ដែលមានបញ្ជាក់នីត្យានុកូលកម្ម មិនមែនគ្រាន់តែថតចម្លង (កូពី) ជាការស្រេចនោះទេ។

សេចក្តីបំភ្លឺខាងលើនេះ ក៏បានអះអាងផងដែរថា គ.ជ.ប អនុវត្តស្តង់ដារតែមួយ តាំងពីការបោះឆ្នោតជ្រើសតាំងតំណាង-រាស្ត្រ នីតិកាលទី៦ ឆ្នាំ២០១៨ ចំពោះគ្រប់គណបក្សនយោបាយដែលមានបំណងចូលរួមប្រកួតប្រជែងការបោះឆ្នោតដោយឯករាជ្យ សេរី ត្រឹមត្រូវ យុត្តិធម៌ និងស្មើភាព។

សូមជម្រាបជូនថា ការដាក់ និងការទទួលពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិ-កាលទី៧ ឆ្នាំ២០២៣ បានប្រព្រឹត្តទៅរយៈពេល ១៥ ថ្ងៃ គឺចាប់ផ្តើមកាលពីថ្ងៃទី២៤ ខែមេសា ដល់ថ្ងៃទី៨ ខែឧសភា ឆ្នាំ២០២៣ ដោយមានគណបក្សនយោបាយ ចំនួន ២០ គណបក្ស បានដាក់ពាក្យសុំចុះបញ្ជីនៅ គ.ជ.ប។ ក្នុងនោះ បញ្ជីគណបក្សនយោបាយចំនួន ១៨ គណបក្ស ត្រូវបានសម្រេចទទួលស្គាល់ជាផ្លូវការដោយ គ.ជ.ប និងបញ្ជីគណបក្សនយោបាយ ចំនួន ២ គណបក្សផ្សេងទៀត គឺគណបក្ស ភ្លើងទៀន និងគណបក្សមហាសាមគ្គី-ជាតិខ្មែរ ត្រូវបានសម្រេចបដិសេធ៕

# គ.ជ.ប រៀបចំកម្មវិធីស្វែងយល់អំពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ តាមវិទ្យុ FM ទូទាំង ២៥ រាជធានី ខេត្ត

ខណៈដែលការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ កាន់តែខិតជិតមកដល់ គណៈកម្មា-ធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) បានរៀបចំកម្មវិធីស្វែងយល់អំពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ ដែលកម្មវិធីនេះនឹងផ្សព្វផ្សាយតាមវិទ្យុ FM ទូទាំង ២៥ រាជធានី ខេត្ត។

ការរៀបចំកម្មវិធីស្វែងយល់អំពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ មានគោលបំណងដើម្បីលើកកម្ពស់ការយល់ដឹងអំពីសារៈសំខាន់នៃការចូលរួមរបស់ប្រជាពលរដ្ឋក្នុងសង្គមប្រជាធិបតេយ្យ សារៈសំខាន់នៃការបោះ-

ឆ្នោត និងលើកទឹកចិត្តដល់អ្នកបោះឆ្នោតឱ្យអញ្ជើញទៅបោះឆ្នោត នៅថ្ងៃអាទិត្យ ទី២៣ ខែកក្កដា ខាងមុខនេះ។

វាគ្មិន ដែលអញ្ជើញចូលរួមក្នុងកម្មវិធីនេះ គឺជាតំណាងមកពីគណៈកម្មការរៀបចំការបោះឆ្នោតនៃរាជធានី ខេត្តសាមីនីមួយៗ ដែលពួកគាត់នឹងធ្វើអត្ថាធិប្បាយ និងចាំទទួលសំណួររបស់មិត្តអ្នកស្តាប់ ហើយឆ្លើយតប។

ខាងក្រោមនេះ គឺជាតារាងពេលវេលាសម្រាប់ការផ្សាយផ្ទាល់កម្មវិធីស្វែងយល់អំពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ តាមវិទ្យុ FM ក្នុងរាជធានី ខេត្តនីមួយៗ ចាប់ពីថ្ងៃទី២០ ខែឧសភា ដល់ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២៣៖

| ល.រ | រាជធានី ខេត្ត | ឈ្មោះស្ថានីយវិទ្យុ | ម៉ោងផ្សាយ |
|---|---|---|---|
| ១ | បន្ទាយមានជ័យ | វិទ្យុជាតិ FM ៩៤ MHz ខេត្តបន្ទាយមានជ័យ | ម៉ោង ៥-៦ ល្ងាច |
| ២ | បាត់ដំបង | វិទ្យុខេមរា FM ៩១ MHz ខេត្តបាត់ដំបង | ម៉ោង ៦-៧ ល្ងាច |
| ៣ | កំពង់ចាម | វិទ្យុជាតិភ្នំប្រុសភ្នំស្រី FM ៩២.៥០ MHz | ម៉ោង ៤-៥ ល្ងាច |
| ៤ | កំពង់ឆ្នាំង | វិទ្យុជាតិភ្នំក្រាំងដីមាស FM ៩២.៣០ MHz | ម៉ោង ៦-៧ យប់ |
| ៥ | កំពង់ស្ពឺ | វិទ្យុលីសាលីណា FM ៩៦.៣០ MHz | ម៉ោង ៥-៦ ល្ងាច |
| ៦ | កំពង់ធំ | វិទ្យុជាតិ FM ៩៨.៣ MHz | ម៉ោង ៥-៦ ល្ងាច |
| ៧ | កំពត | វិទ្យុជាតិ ៩ មករា FM ៩៩.៧០ MHz ខេត្តកំពត | ម៉ោង ១០-១១ ព្រឹក |
| ៨ | កណ្តាល | វិទ្យុ PSN ៩៥.៣ MHz | ម៉ោង ៤-៥ ល្ងាច |
| ៩ | កោះកុង | វិទ្យុសាគរកោះកុង FM ៩៤.៥ MHz | ម៉ោង ៥-៦ ល្ងាច |
| ១០ | ក្រចេះ | វិទ្យុបុប្ផាខេត្តក្រចេះ FM ១០៥ MHz | ម៉ោង ៥-៦ ល្ងាច |
| ១១ | មណ្ឌលគិរី | វិទ្យុជាតិ FM ៩៧ MHz ខេត្តមណ្ឌលគិរី | ម៉ោង ១-២ រសៀល |
| ១២ | ភ្នំពេញ | វិទ្យុរាជធានីភ្នំពេញ FM ១០៣ MHz | ម៉ោង ១-២ រសៀល |
| ១៣ | ព្រះវិហារ | វិទ្យុ FM ជាតិភ្នំត្បែង FM ៩៧ MHz | ម៉ោង ៦-៧ ល្ងាច |
| ១៤ | ព្រៃវែង | វិទ្យុមហាសាល FM ៩៩.២៥ MHz | ម៉ោង ១១-១២ ថ្ងៃត្រង់ |
| ១៥ | ពោធិ៍សាត់ | វិទ្យុជាតិ FM ៩៨.៥០ MHz ខេត្តពោធិ៍សាត់ | ម៉ោង ៥-៦ ល្ងាច |
| ១៦ | រតនគិរី | វិទ្យុសុខសាន្តមនោរម្យ FM ៨៨.៥ MHz | ម៉ោង ១-២ រសៀល |
| ១៧ | សៀមរាប | វិទ្យុ FM ជាតិនគរភ្នំ ១០៣ MHz | ម៉ោង ៥-៦ ល្ងាច |

| | | | |
|---|---|---|---|
| ១៨ | ព្រះសីហនុ | វិទ្យុជាតិកំពង់សោម FM ៩៣ MHz | ម៉ោង ៥:៣០ -៦:៣០ល្ងាច |
| ១៩ | ស្ទឹងត្រែង | វិទ្យុជាតិសេកុង FM ៩៩ MHz ខេត្តស្ទឹងត្រែង | ម៉ោង ៥-៦ ល្ងាច |
| ២០ | ស្វាយរៀង | វិទ្យុជាតិវំដួលស្វាយរៀង FM ៩៨.៧០ MHz | ម៉ោង ៩-១០ ព្រឹក |
| ២១ | តាកែវ | វិទ្យុជាតិ FM ៩២.៥ គោកធ្លក | ម៉ោង ១២-១ ថ្ងៃត្រង់ |
| ២២ | កែប | វិទ្យុជាតិឆ្នេរកែប FM ៩៩.០០ MHz | ម៉ោង ១០-១១ ថ្ងៃត្រង់ |
| ២៣ | ប៉ៃលិន | វិទ្យុអូរតង់ប៉ៃលិន FM ៩៧.៥ MHz | ម៉ោង ៦-៧ ល្ងាច |
| ២៤ | ឧត្តរមានជ័យ | វិទ្យុជាតិ FM ៩០ MHz ខេត្តឧត្តរមានជ័យ | ម៉ោង ៦-៧ ល្ងាច |
| ២៥ | ត្បូងឃ្មុំ | វិទ្យុជាតិត្បូងឃ្មុំ FM ៨៨ MHz | ម៉ោង ១១-១២ ថ្ងៃត្រង់ |

# វគ្គបណ្តុះបណ្តាលគ្រូបង្គោល និងភ្នាក់ងារសន្តិសុខបោះឆ្នោត អំពីច្បាប់ស្តីពីការបោះឆ្នោត បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោត និងក្រមសីលធម៌សម្រាប់ភ្នាក់ងារសន្តិសុខបោះឆ្នោត ត្រូវបានបិទបញ្ចប់

វគ្គបណ្តុះបណ្តាលគ្រូបង្គោល និងភ្នាក់ងារសន្តិសុខបោះឆ្នោតរយៈពេល ៣ ថ្ងៃ អំពី **ច្បាប់ស្តីពីការបោះឆ្នោត បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោត និងក្រមសីលធម៌សម្រាប់ភ្នាក់ងារសន្តិសុខបោះឆ្នោត** សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ ដែលរៀបចំឡើងក្រោមកិច្ចសហការរវាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) និងលេខាធិការដ្ឋាននៃគណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍សម្រាប់ការបោះឆ្នោត (គ.ស.អ) ត្រូវបានបិទបញ្ចប់នៅរសៀលថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២៣ នៅអគ្គស្នងការដ្ឋាននគរបាលជាតិ។

ឯកឧត្តម **ទេព នីថា** អគ្គលេខាធិការ គ.ជ.ប ក្នុងឱកាសអញ្ជើញជាអធិបតីក្នុងពិធីបិទវគ្គបណ្តុះបណ្តាលនេះ បានថ្លែងថា ផ្អែកតាមច្បាប់ស្តីពីការបោះឆ្នោតជាធរមាន និងបទបញ្ជា និងនីតិវិធីសម្រាប់ការពិនិត្យបញ្ជីឈ្មោះនិងការចុះឈ្មោះបោះឆ្នោត



សកម្មភាពក្នុងពិធីបិទវគ្គបណ្តុះបណ្តាល



**ឯកឧត្តម ទេព នីថា អគ្គលេខាធិការ គ.ជ.ប**

និងការបោះឆ្នោត ដំណើរការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ត្រូវបែងចែកជា ៤ ដំណាក់កាលសំខាន់ៗ រួមមាន៖

ទី១- ដំណាក់កាលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ឆ្នាំ២០២២ ដើម្បីរៀបចំបញ្ជីបោះឆ្នោត សម្រាប់បម្រើឱ្យការបោះឆ្នោតជ្រើស-តាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣។ ដំណើរការនេះត្រូវបានអនុវត្តតាំងពីខែតុលា ឆ្នាំ២០២២ និងបានបិទបញ្ចប់ កាលពីថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៣ ប្រកបដោយភាពជោគជ័យ និងក្នុងបរិយាកាសស្ងប់ស្ងាត់ មានសន្តិសុខ និងសុវត្ថិភាពល្អ។

ទី២- ដំណាក់កាលនៃការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ។ ដំណើរការទទួលពាក្យសុំចុះបញ្ជីមានរយៈពេល ១៥ ថ្ងៃ ចាប់ផ្តើមនៅថ្ងៃទី២៤ ខែមេសា និងបានបញ្ចប់កាលពីថ្ងៃទី៨ ខែឧសភា ឆ្នាំ២០២៣ កន្លង-



**សកម្មភាពក្នុងពិធីបិទវគ្គបណ្តុះបណ្តាល**

ទៅថ្មីៗនេះ ដែលមានគណបក្សនយោបាយដាក់ពាក្យសុំចុះបញ្ជីសរុបចំនួន ២០ គណបក្ស។ ក្នុងនោះ គ.ជ.ប បានសម្រេចយល់ព្រមជាផ្លូវការចំនួន ១៣ គណបក្ស ដែលមានបេក្ខជនពេញសិទ្ធិសរុប ១.២២២ រូប (ស្ត្រី ៣៥៦ រូប) និងបេក្ខជនបម្រុងសរុប ១.៣៧២ រូប (ស្ត្រី ៤៨១ រូប) ។ បច្ចុប្បន្ន គ.ជ.ប បាននិងកំពុងដំណើរការពិនិត្យឯកសារ និងលក្ខខណ្ឌចុះបញ្ជីរបស់គណបក្សនយោបាយមួយចំនួនទៀត ស្របតាមការកំណត់នៃច្បាប់ស្តីពីការបោះឆ្នោត។

ទី៣- ដំណាក់កាលឃោសនាបោះឆ្នោត ដែលមានរយៈ-ពេល ២១ ថ្ងៃ គិតចាប់ពីថ្ងៃទី១ ដល់ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២៣។



**សកម្មភាពក្នុងពិធីបិទវគ្គបណ្តុះបណ្តាល**

ទី៤- ដំណាក់កាលបោះឆ្នោត រាប់សន្លឹកឆ្នោត និងប្រកាសលទ្ធផលនៃការបោះឆ្នោត។

ឯកឧត្តមបានមានប្រសាសន៍ថា គ្រប់ដំណាក់កាលនីមួយៗ អាចប្រព្រឹត្តទៅបានដោយជោគជ័យ មានសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់ល្អ គឺអាស្រ័យដោយមានកិច្ចសហការពីយន្តការ រចនាសម្ព័ន្ធសន្តិសុខបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ជាពិសេសលេខាធិការដ្ឋាននៃគណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍សម្រាប់ការបោះឆ្នោត និងការអនុវត្តតួនាទី និងភារកិច្ចប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់របស់គណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍រាជធានី ខេត្តសម្រាប់ការបោះឆ្នោត អាជ្ញាធរដែនដី កងកម្លាំងមានសមត្ថកិច្ច និងភ្នាក់ងារសន្តិសុខបោះឆ្នោតទាំង-

អស់។ ហេតុដូច្នេះហើយ ដើម្បីធានាប្រសិទ្ធភាពការងារនេះ ទើបតម្រូវឱ្យកម្លាំងមានសមត្ថកិច្ច និងភ្នាក់ងារសន្តិសុខបោះឆ្នោតមានការយល់ដឹងបានល្អ ច្បាស់លាស់អំពីច្បាប់ស្តីពីការបោះឆ្នោតបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោត និងក្រមសីលធម៌សម្រាប់ភ្នាក់ងារសន្តិសុខបោះឆ្នោត។

ឯកឧត្តម **ទេព នីថា** បានលើកឡើងទៀតថា វគ្គបណ្តុះ-បណ្តាលលើកនេះមានលក្ខណៈពិសេស និងខុសប្លែកពីវគ្គបណ្តុះ-បណ្តាលមុនៗ ដោយលើកនេះ លេខាធិការដ្ឋាននៃគណៈបញ្ជា-ការសន្តិសុខអចិន្ត្រៃយ៍សម្រាប់ការបោះឆ្នោត និង គ.ជ.ប បានសហការគ្នារៀបចំធ្វើការបណ្តុះបណ្តាលដល់គ្រូបង្គោល និងភ្នាក់ងារសន្តិសុខបោះឆ្នោត ក្នុងជួរយន្តការ រចនាសម្ព័ន្ធសន្តិសុខបោះឆ្នោតនៅថ្នាក់ជាតិ និងរាជធានី ខេត្ត ដើម្បីបន្តបណ្តុះបណ្តាលនៅតាមអង្គភាពពាក់ព័ន្ធ និងនៅតាមមូលដ្ឋាននៃរាជធានី ខេត្តនីមួយៗរៀងៗខ្លួន។

ឯកឧត្តមអគ្គលេខាធិការ គ.ជ.ប សង្ឃឹមយ៉ាងមុតមាំថា សិក្ខាកាមទាំងអស់នឹងទទួលបាននូវចំណេះដឹង ព្រមទាំងបទ-ពិសោធន៍ថ្មីៗបន្ថែមទៀត ដើម្បីយកទៅអនុវត្តសម្រាប់យុទ្ធនា-ការការពារដំណើរការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ នេះ ឱ្យមានប្រសិទ្ធភាព និងទទួលបាននូវលទ្ធផលល្អប្រសើរ ក្នុងបរិយាកាសស្ងប់ស្ងាត់ មានសន្តិសុខ សុវត្ថិភាព គ្មានការបំភិតបំភ័យ គ្មានអំពើហិង្សា និងគ្មានការគំរាមកំហែង។



សកម្មភាពក្នុងពិធីបិទវគ្គបណ្តុះបណ្តាល

សូមជម្រាបជូនថា វគ្គបណ្តុះបណ្តាលនេះ មានសិក្ខាកាមចូលរួមជាគ្រូបង្គោលនៃគណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍សម្រាប់ការបោះឆ្នោត មកពី ២៥ រាជធានី ខេត្ត និងមន្ត្រីបោះឆ្នោតនៃទីស្តីការ គ.ជ.ប សរុបប្រមាណ ១៨០ នាក់៕

# គ.ជ.ប ណែនាំអំពីកិច្ចសហការការពារសន្តិសុខ សុវត្ថិភាព និង សណ្តាប់ធ្នាប់សាធារណៈ សម្រាប់ដំណើរការបោះឆ្នោត ជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣

ក្នុងគោលបំណងឱ្យដំណើរការនៃការបោះឆ្នោតជ្រើស-តាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ ប្រព្រឹត្តទៅដោយរលូន និងទទួលបានជោគជ័យ ស្ថិតក្នុងការធានាបាននូវបរិយា-កាសសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់ល្អ គ្មានការបំភិត-បំភ័យ គ្មានការគំរាមកំហែង និងគ្មានអំពើហិង្សា គណៈកម្មាធិ-ការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) កាលពីថ្ងៃទី៩ ខែឧសភា ឆ្នាំ២០២៣ តាមរយៈសេចក្តីណែនាំលេខ ០៣៤ គ.ជ.ប.ស.ណ.ន បានណែនាំដល់លេខាធិការដ្ឋានសន្តិសុខបោះឆ្នោតនៃ គ.ជ.ប គណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត (គធ.ខប) គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត (គឃ.សប) ឱ្យយកចិត្តទុកដាក់សហការអនុវត្តតាមគោលការណ៍និងវិធានការដូចខាងក្រោម៖

១. លេខាធិការដ្ឋានសន្តិសុខបោះឆ្នោតនៃ គ.ជ.ប និង គធ.ខប ត្រូវសហការ និងពិគ្រោះយោបល់ជាមួយ

លេខាធិការដ្ឋាន នៃគណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍ សម្រាប់ការបោះឆ្នោត និងគណៈអភិបាលរាជធានី ខេត្ត ដែលជាគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្នុងការចាត់ចែងរៀបចំកម្លាំងនគរបាល ឬ/និង កងរាជអាវុធហត្ថ ឬ/និងកងយោធពលខេមរភូមិន្ទ ដែលមានមូលដ្ឋានឈរជើងនៅតាមរាជធានី ខេត្ត ឱ្យបំពេញភារកិច្ចជាភ្នាក់ងារសន្តិសុខបោះឆ្នោត តាមដំណាក់កាលនីមួយៗ ដើម្បីការពារមុខសញ្ញា និងគោលដៅសំខាន់ៗ ផ្អែកតាមចំនួនកម្លាំងដែលបានកំណត់ក្នុងផែនការអន្តរស្ថាប័នលេខ ០១០ ផ.ក ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២១ និងសេចក្តីណែនាំរួមលេខ ០១ សណន ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០២៣ និងចាត់វិធានការនានា ការពារសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់ សម្រាប់ដំណើរការនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ ដោយអនុលោមតាមច្បាប់ស្តីពីការបោះឆ្នោតជ្រើស-តាំងតំណាងរាស្ត្រ បទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប ព្រមទាំងផែនការ ឬក៏សេចក្តីណែនាំផ្សេងៗទៀត ដែលពាក់ព័ន្ធនឹងការងារសន្តិសុខ។

២. គធ.ខប និង គឃ.សប នីមួយៗត្រូវពង្រឹងកិច្ច-សហការឱ្យបានជាប់ជាប្រចាំជាមួយគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ដែលមានស្នងការដ្ឋាននគរបាលរាជធានី ខេត្ត ជាសេនាធិការ ពិសេសកម្លាំងការពារក្នុងពេលឃោសនាបោះឆ្នោត ការពារទីស្នាក់-ការ គឃ.សប ការពារការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត កម្លាំងត្រៀមអន្តរាគមន៍ភូមិសាស្ត្រខាងក្រៅក្នុងក្រុង ស្រុក ខណ្ឌនីមួយៗ និងកម្លាំងត្រៀមអន្តរាគមន៍ នៅនឹងកន្លែងនៅតាមបញ្ជាការដ្ឋានយោធភូមិភាគនៃរាជធានី ខេត្តដែលពាក់ព័ន្ធ ដោយផ្អែកតាមផែនការកំណត់។

៣. គធ.ខប និង គឃ.សប នីមួយៗ ត្រូវយកចិត្តទុក-ដាក់តាមដាន និងបង្កើនការផ្លាស់ប្តូរព័ត៌មានអំពីសភាពការណ៍សន្តិសុខទូទៅ និងត្រូវស្នើសុំកិច្ចអន្តរាគមន៍ពីកម្លាំងមានសមត្ថកិច្ច ក្រុមពន្លត់អគ្គិភ័យ ឬក្រុមបុគ្គលិកសុខាភិបាលឱ្យបានទាន់ពេលវេលា ក្នុងករណីមានការអុកឡុកវុំខាន ការគំរាមកំហែង ឬការប្រព្រឹត្តអំពើល្មើសច្បាប់ផ្សេងៗ ឬមានអគ្គិភ័យ ឬបញ្ហាសុខភាពផ្សេងៗទៀត ដែលអាចធ្វើឱ្យរាំងស្ទះដល់ដំណើរការនៃការបោះឆ្នោតជ្រើសតាំងតំណាង-រាស្ត្រ។

៤. ក្នុងដំណើរការរៀបចំការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ប្រសិនបើប្រទេសជាតិជួបគ្រោះអាសន្ន ឬស្ថានភាពនៃការឆ្លងរីករាលដាលនៃជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងៗ វិធានការសុខាភិបាល វិធានការរដ្ឋបាល និងវិធាន-ការចាំបាច់នានាត្រូវអនុវត្តដោយ គ.ជ.ប និងគណៈ-កម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

៥. ចាប់ពីពេលនេះ រហូតចប់ការបោះឆ្នោតជ្រើសតាំង-តំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ គធ.ខប នីមួយៗ ត្រូវស្នើសុំកិច្ចសហការពីគណៈអភិបាលរាជធានី ខេត្ត ដែលជាគណៈបញ្ជាការឯកភាពរដ្ឋ-បាលរាជធានី ខេត្ត ដើម្បីរៀបចំកិច្ចប្រជុំចម្រុះដោយផ្ទាល់ ឬតាមប្រព័ន្ធអនឡាញ (Online) ម្តងក្នុងមួយសប្តាហ៍ និងអាចកោះប្រជុំតាមការចាំបាច់ក្នុងគោលបំណងពិភាក្សាលើការងារសន្តិសុខ និងការចាត់វិធានការចាំបាច់ផ្សេងៗ សំដៅកាត់បន្ថយឱ្យបានរាល់បញ្ហាទំនាស់ ឬការប្រឈមនានាដែលកើត

មានឡើង និងត្រូវស្វែងរកដំណោះស្រាយឱ្យបានសមស្រប។

៦. គជ.ឃប នីមួយៗ ត្រូវធ្វើរបាយការណ៍ជាប្រចាំជុំវិញស្ថានការណ៍សន្តិសុខជាទូទៅ ដែលបានកើតឡើងនៅតាមរាជធានី ខេត្តនីមួយៗ ក្នុងអំឡុងពេលនៃដំណើរការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ ផ្ញើជូនលេខាធិការដ្ឋាន-សន្តិសុខបោះឆ្នោតនៃ គ.ជ.ប ឱ្យបានទៀងទាត់ ដើម្បីរាយការណ៍ជូន គ.ជ.ប ជ្រាប។ ក្នុងករណីចាំបាច់ គជ.ឃប នីមួយៗត្រូវរាយការណ៍ផ្ទាល់ជូនប្រធានលេខាធិការដ្ឋានសន្តិសុខបោះឆ្នោតនៃ គ.ជ.ប ដើម្បីស្នើសុំគោលការណ៍សម្រេចពីថ្នាក់ដឹកនាំ គ.ជ.ប និងមានវិធានការដោះស្រាយបានទាន់ពេលវេលា និងស្របតាមនីតិវិធី។

សូមជម្រាបជូនថា ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ នឹងប្រព្រឹត្តទៅនៅថ្ងៃអាទិត្យ ទី២៣ ខែកក្កដា ឆ្នាំ២០២៣។ មុនដល់ថ្ងៃបោះឆ្នោត គណបក្សនយោបាយទាំងអស់ ដែលបានដាក់បេក្ខជនឈរឈ្មោះបោះឆ្នោតតាមមណ្ឌលរាជធានី ខេត្ត នឹងបើកយុទ្ធនាការឃោសនារកសំឡេងឆ្នោត ដែលកាលបរិច្ឆេទនៃការឃោសនាបោះឆ្នោត ត្រូវចាប់ផ្តើមពីថ្ងៃទី១ ដល់ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២៣៕

# ប្រធាន គ.ជ.ប ទទួលជួបឯកអគ្គរដ្ឋទូតអូស្ត្រាលី ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា

ឆ្លើយតបតាមសំណើសុំជួបពិភាក្សាការងាររបស់ឯកអគ្គរដ្ឋទូតអូស្ត្រាលី នាព្រឹកថ្ងៃទី៥ ខែឧសភា ឆ្នាំ២០២៣ វេលាម៉ោង ១០:០០ នៅទីស្តីការគណៈកម្មាធិការជាតិរៀបចំការ-បោះឆ្នោត (គ.ជ.ប) ឯកឧត្តម **ប្រាជ្ញ ចន្ទ** ប្រធាន គ.ជ.ប បានទទួលជួបសវនាការជាមួយ ឯកឧត្តម **ចាស្ទីន វ៉ាយអេត** (H.E. Justin Whyatt) ឯកអគ្គរដ្ឋទូតអូស្ត្រាលីប្រចាំនៅព្រះរាជាណា-ចក្រកម្ពុជា ដើម្បីចូលជួបសម្តែងការគួរសម និងពិភាក្សាការងារពាក់ព័ន្ធនឹងការរៀបចំការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣។

ជាកិច្ចចាប់ផ្តើម ឯកឧត្តម **ប្រាជ្ញ ចន្ទ** បានមានមតិស្វា-គមន៍ចំពោះឯកឧត្តមឯកអគ្គរដ្ឋទូតអូស្ត្រាលី ដែលបានអញ្ជើញមកដល់ទីស្តីការ គ.ជ.ប ដើម្បីជួបពិភាក្សាការងារពាក់ព័ន្ធនឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧។ ឯកឧត្តម



សកម្មភាពក្នុងជំនួបពិភាក្សា

ប្រធាន គ.ជ.ប បានថ្លែងអំណរគុណដល់អូស្ត្រាលីដែលបានជួយដល់ការបោះឆ្នោតនៅកម្ពុជានាពេលកន្លងមក នូវថវិកាជិតមួយលានដុល្លារសហរដ្ឋអាមេរិក។

ឯកឧត្តម **ចាស្ទីន វ៉ាយអេត** បានថ្លែងអំណរគុណដល់ឯកឧត្តមប្រធាន គ.ជ.ប ដែលបានចំណាយពេលវេលាទទួល

ជួប ហើយឯកឧត្តមបានរំលឹកអំពីបេសកកម្មនៅប្រទេសកម្ពុជា ចូលរួមមើលការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ឆ្នាំ២០០២ និងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រឆ្នាំ២០០៣។ សម្រាប់ឆ្នាំ២០២៣ នេះ ឯកឧត្តមឯកអគ្គរដ្ឋទូតមានឱកាសម្តងទៀតមកស្វែងយល់ពីការបោះឆ្នោតនៅកម្ពុជា។ ឯកឧត្តមឯកអគ្គរដ្ឋទូតបានចាប់អារម្មណ៍អំពីការវិវឌ្ឍផ្នែកនយោបាយ និងការអភិវឌ្ឍរបស់ប្រទេសកម្ពុជានាពេលបច្ចុប្បន្ន។ ឯកឧត្តមឯកអគ្គរដ្ឋទូតបានវាយតម្លៃខ្ពស់អំពីតួនាទីយ៉ាងសំខាន់របស់ គ.ជ.ប ក្នុងការរៀបចំការបោះឆ្នោតតាមបែបលក្ខណៈប្រជាធិបតេយ្យ ដែលត្រូវធ្វើយ៉ាងណាឱ្យការបោះឆ្នោតមានភាពអព្យាក្រឹត ឥតលម្អៀង និងមានភាពជឿជាក់ពីម្ចាស់ឆ្នោត។ ឯកឧត្តម



**សកម្មភាពក្នុងជំនួបពិភាក្សា**

ឯកអគ្គរដ្ឋទូតបានបន្តថា ការបោះឆ្នោតតាមបែបប្រជាធិបតេយ្យ មិនមែនសំខាន់តែក្នុងថ្ងៃបោះឆ្នោតទេ ប្រជាធិបតេយ្យមានតាំងពីមុនការបោះឆ្នោត និងក្រោយការបោះឆ្នោត ។

ក្នុងជំនួបនាពេលនោះ ឯកឧត្តម **ចាស្ទីន វ៉ាយអេត** ចង់ដឹងអំពីដំណើរការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ និងអំពីបែបបទនៃការចុះបញ្ជីនេះ។ មួយទៀត ឯកឧត្តមឯកអគ្គរដ្ឋទូត ចង់ដឹងអំពីតួនាទីអ្នកសង្កេតការណ៍បោះឆ្នោត ពីព្រោះខាងអូស្ត្រាលីនឹងមិនដាក់អ្នកសង្កេតការណ៍បោះឆ្នោតទេ ប៉ុន្តែអូស្ត្រាលីនឹងជួយអ្នកសង្កេតការណ៍ជាតិនៅកម្ពុជា។



**(រូបខាងស្តាំ) ឯកឧត្តម ប្រាជ្ញ ចន្ទ ប្រធាន គ.ជ.ប និង ឯកឧត្តម ចាស្ទីន វ៉ាយអេត ឯកអគ្គរដ្ឋទូតអូស្ត្រាលីប្រចាំកម្ពុជា**

ឆ្លើយបំភ្លឺទៅនឹងសំណួរខាងលើ ឯកឧត្តម **ប្រាជ្ញ ចន្ទ** បានពន្យល់អំពីប្រវត្តិនៃការបោះឆ្នោតនៅកម្ពុជាតាំងពីឆ្នាំ១៩៩៣ ការបង្កើតសភាជម្មនុញ្ញ តមកសភាជម្មនុញ្ញក្លាយជារដ្ឋសភា និងការបង្កើតរាជរដ្ឋាភិបាល។ មកទល់ពេលនេះ គ.ជ.ប បានរៀបចំការបោះឆ្នោតដោយខ្លួនឯង ចំនួន ១៨ លើករួចមកហើយ ដែលការបោះឆ្នោតទាំងនោះត្រូវបានទទួលស្គាល់ពីភាពត្រឹមត្រូវ យុត្តិធម៌ និងតម្លាភាព។

ឯកឧត្តម **ប្រាជ្ញ ចន្ទ** បានបន្តថា នៅឆ្នាំ២០១៥ ប្រទេសកម្ពុជាបានធ្វើការកែទម្រង់ការបោះឆ្នោត ដោយស្ថាប័ន គ.ជ.ប ត្រូវបានចែងក្នុងរដ្ឋធម្មនុញ្ញ។ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងច្បាប់ស្តីពីការបោះឆ្នោត



**សកម្មភាពក្នុងជំនួបពិភាក្សា**

ជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវបានអនុម័តដោយរដ្ឋសភា។ បច្ចុប្បន្ន គ.ជ.ប កំពុងរៀបចំការបោះឆ្នោតជ្រើសតាំងតំណាង-រាស្ត្រ នីតិកាលទី៧ និងនៅឆ្នាំ២០២៤ ខាងមុខនេះ គ.ជ.ប នឹងត្រូវរៀបចំការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា និងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុម-ប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ។ ការរៀបចំ និងការចាត់ចែងការបោះឆ្នោតទាំងនោះជាសមត្ថកិច្ចរបស់ គ.ជ.ប។

ឯកឧត្តម **ប្រាជ្ញ ចន្ទ** បានមានប្រសាសន៍អំពីការរៀបចំប្រតិទិននៃការបោះឆ្នោត ការធ្វើផែនការមេ ការរៀបចំបទបញ្ញា និងនីតិវិធីនៃការបោះឆ្នោត និងការកសាងឯកសារគតិយុត្តពាក់-ព័ន្ធផ្សេងទៀតសម្រាប់ការបោះឆ្នោត។ឯកឧត្តមប្រធាន គ.ជ.ប បានពន្យល់អំពីដំណាក់កាលនីមួយៗនៃការរៀបចំការបោះឆ្នោតដែលមានតាំងពីការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ ការឃោសនាបោះឆ្នោត ការបោះឆ្នោត និងរាប់សន្លឹកឆ្នោត ការប្រកាសលទ្ធផលនៃការបោះឆ្នោត និងនីតិវិធីនៃការដាក់ពាក្យបណ្ដឹង ការដោះស្រាយពាក្យបណ្ដឹងទាក់ទងនឹងលទ្ធផលនៃការបោះឆ្នោត។

ពាក់ព័ន្ធនឹងការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ ឯកឧត្តម **ប្រាជ្ញ ចន្ទ** បានបញ្ជាក់ជូនថា គណបក្សនយោបាយដែលចុះបញ្ជីស្របច្បាប់នៅក្រសួងមហាផ្ទៃ មានសិទ្ធិដាក់ពាក្យសុំចុះបញ្ជីគណបក្សនយោបាយនៅ គ.ជ.ប ដើម្បីចូលរួមក្នុងការបោះឆ្នោត ដោយត្រូវបំពេញលក្ខខណ្ឌតាមការកំណត់នៃច្បាប់ បទបញ្ញា និងនីតិវិធីនៃការបោះឆ្នោត។ លក្ខខណ្ឌដែលតម្រូវឱ្យគណបក្សនយោបាយបំពេញ មានចែងក្នុងច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាង-រាស្ត្រ ត្រង់មាត្រា ២៧។ ចំពោះការសង្កេតការណ៍បោះឆ្នោត គ.ជ.ប នឹងអញ្ជើញភាគីអន្តរជាតិ ដើម្បីចូលរួមសង្កេតមើលការបោះឆ្នោតនៅកម្ពុជា។ រីឯស្ថានទូតប្រចាំនៅព្រះរាជាណាចក្រ-



រូបថតអនុស្សាវរីយ៍

កម្ពុជា គ.ជ.ប នឹងអញ្ជើញចូលរួមសង្កេតមើលការបោះឆ្នោត ជាភ្ញៀវពិសេស។

ចំពោះការបណ្ដុះបណ្ដាល និងការផ្សព្វផ្សាយអប់រំអ្នកបោះឆ្នោត ឯកឧត្តម **ប្រាជ្ញ ចន្ទ** បានគូសបញ្ជាក់ថា ថ្មីៗនេះ គ.ជ.ប ទើបតែបញ្ចប់ការបណ្ដុះបណ្ដាលស្ដីពី ការឃោសនាបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ ដែលអញ្ជើញចូលរួមក្នុងវគ្គនោះ រួមមាន៖ មន្ត្រីបោះឆ្នោតទាំង ២៥ រាជធានី ខេត្ត តំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធ តំណាងគណបក្សនយោបាយ តំណាងសមាគម និងតំណាងអង្គការ-មិនមែនរដ្ឋាភិបាល។ បន្ទាប់ពីនេះ ភាគីពាក់ព័ន្ធនឹងធ្វើការបណ្ដុះបណ្ដាលជាបន្តទៀតដល់អ្នកពាក់ព័ន្ធក្នុងអង្គភាព ឬស្ថាប័នរបស់ខ្លួន។

ជាចុងក្រោយ ឯកឧត្តម **ចាស្ទីន វ៉ាយអេត** បានថ្លែងអំណរគុណដល់ ឯកឧត្តម **ប្រាជ្ញ ចន្ទ** ដែលបានជម្រាបជូនអំពីដំណើរការរៀបចំការបោះឆ្នោតនៅកម្ពុជាប្រព្រឹត្តទៅបានយ៉ាងល្អប្រសើរ។ ឯកឧត្តម **ប្រាជ្ញ ចន្ទ** ក៏បានជូនពរឱ្យការបំពេញបេសកកម្មរបស់ឯកអគ្គរដ្ឋទូតអូស្ត្រាលីនៅព្រះរាជាណាចក្រ-កម្ពុជាប្រកបដោយជោគជ័យ។

ជំនួបពិភាក្សាការងារបានប្រព្រឹត្តទៅអស់រយៈពេល ១ ម៉ោង ប្រកបដោយភាពស្និទ្ធស្នាល និងយោគយល់គ្នា។

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ



គ.ជ.ប

# ខិត្តប័ណ្ណស្តីពី
## ការបោះឆ្នោតដោយសម្ងាត់ សេរី យុត្តិធម៌ និងតម្លាភាព

### ការបោះឆ្នោត និងសិទ្ធិចូលរួមបោះឆ្នោត៖

- បោះឆ្នោតដោយ "សម្ងាត់" មានន័យថា ការសម្ងាត់របស់អ្នកបោះឆ្នោតត្រូវបានធានាដោយអ្នកបោះឆ្នោតចូលបោះឆ្នោតក្នុងបន្ទប់សម្ងាត់គ្មាននរណាម្នាក់អាចដឹងថាយើងបោះឆ្នោតឱ្យគណបក្សណាមួយឡើយ។ សន្លឹកឆ្នោតមានលក្ខណៈដូចគ្នាគ្មានអ្វីសម្គាល់ដឹងថាសន្លឹកឆ្នោតនេះជារបស់អ្នកបោះឆ្នោតម្នាក់នេះ ហើយសន្លឹកឆ្នោតនោះជារបស់អ្នកបោះឆ្នោតម្នាក់នោះទេ។
- បោះឆ្នោតតាម "ឆន្ទៈ" មានន័យថា អ្នកបោះឆ្នោតត្រូវសម្រេចចិត្តបោះឆ្នោតជ្រើសរើសតំណាងតាមការស្រឡាញ់ពេញចិត្តរបស់ខ្លួន។
- បោះឆ្នោតដោយ "សេរី" មានន័យថា៖
  - សេរីភាពទទួលបានព័ត៌មានអំពីការបោះឆ្នោត និងព័ត៌មានផ្សេងៗដោយសេរី និងតម្លាភាព
  - មានការបញ្ចេញមតិយោបល់ ដើម្បីពិភាក្សាអំពីបេក្ខជន បេក្ខនារីនៃគណបក្សនយោបាយលេះឈ្មោះបោះឆ្នោត
  - មានការចូលរួមប្រជុំដោយសេរី និងការប្រើប្រាស់មធ្យោបាយផ្សព្វផ្សាយដោយសេរី និងស្មើភាព
  - អ្នកបោះឆ្នោតអាចទទួលព័ត៌មានអំពីដំណើរការបោះឆ្នោតដោយសេរី និងគ្រប់ដំណើរការនៃការបោះឆ្នោត។
- បោះឆ្នោតដោយ "យុត្តិធម៌" មានន័យថា៖
  - បោះឆ្នោតដោយសម្ងាត់ គ្មានការក្លែងបន្លំសន្លឹកឆ្នោត គ្មានការលួចដូរសន្លឹកឆ្នោត និងគ្មានការបន្លំលទ្ធផលបោះឆ្នោត
  - គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតប្រកាន់ខ្ជាប់នូវគោលជំហរឯករាជ្យ អព្យាក្រឹត សច្ចៈ យុត្តិធម៌ និងតម្លាភាព
  - ការដោះស្រាយវិវាទបោះឆ្នោត ប្រកបដោយតម្លាភាព យុត្តិធម៌ និងត្រឹមត្រូវតាមច្បាប់កំណត់។

### ដើម្បីបោះឆ្នោតបាន ប្រជាពលរដ្ឋខ្មែរទាំងពីរគេនត្រូវ៖

- មានឈ្មោះក្នុងបញ្ជីបោះឆ្នោតផ្លូវការឆ្នាំ២០២២ ដែលបានផ្តល់សុពលភាពដោយ គ.ជ.ប សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៧ ឆ្នាំ២០២៣
- មានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ (អ.ខ) ដែលមានសុពលភាព ឬឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការបោះឆ្នោត (ឯ.អ)

### នីតិវិធីនៃការស្នើសុំឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការបោះឆ្នោត (ឯ.អ)៖

ករណីប្រជាពលរដ្ឋមានឈ្មោះក្នុងបញ្ជីបោះឆ្នោតផ្លូវការ ឆ្នាំ២០២២ ប៉ុន្តែពុំមាន អ.ខ ឬខូច ឬបាត់ ឬ អ.ខ បានអស់សុពលភាព ឬមិនទាន់ទទួលបាន ដើម្បីបោះឆ្នោតប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោត អាចស្នើសុំ ឯ.អ តាមលក្ខខណ្ឌដូចខាងក្រោម៖

- ត្រូវស្នើសុំក្នុងរយៈពេល៣០ថ្ងៃ ដោយគិតចាប់ពី **ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២៣** ដល់ **ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២៣** វេលាម៉ោង១៧:៣០ នាទី ជាកំហិត
- ត្រូវបង្ហាញខ្លួនដោយផ្ទាល់នៅចំពោះមុខ គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត (គឃ.សប) នៃឃុំ សង្កាត់ដែលសាមីខ្លួនមានឈ្មោះក្នុងបញ្ជីបោះឆ្នោតផ្លូវការ និងត្រូវបោះឆ្នោត
- ត្រូវបំពេញពាក្យស្នើសុំ និងត្រូវផ្តិតស្នាមម្រាមដៃនៅចំពោះមុខប្រធាន គឃ.សប
- ត្រូវផ្តល់ស្នាមម្រាមដៃតាមការណែនាំរបស់សមាជិក គឃ.សប ទទួលបន្ទុកលើការងាររដ្ឋបាល និងថតរូបសម្រាប់ផ្ទៀងផ្ទាត់ និងទាញទិន្នន័យពីបញ្ជីបោះឆ្នោតផ្លូវការក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យអ្នកបោះឆ្នោត និងបញ្ជីបោះឆ្នោត។
- សាមីខ្លួនត្រូវយកទម្រង់ ឯ.អ ដែលបានបោះត្រា និងចុះហត្ថលេខាដោយ គឃ.សប ទៅជួបមេឃុំ ចៅសង្កាត់ដើម្បីចុះហត្ថលេខា និងបោះត្រាផ្តល់សុពលភាពប្រើប្រាស់ជាផ្លូវការ។

**សូមអញ្ជើញបងប្អូនប្រជាពលរដ្ឋខ្មែរដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតផ្លូវការ ឆ្នាំ២០២២**
**ទៅចូលរួមបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ដែលប្រព្រឹត្តទៅនៅ**
**ថ្ងៃអាទិត្យ ទី២៣ ខែកក្កដា ឆ្នាំ២០២៣ ចាប់ពីម៉ោង ៧:០០ ព្រឹក ដល់ម៉ោង ៣:០០ រសៀល**
**នៅតាមការិយាល័យបោះឆ្នោតក្នុងឃុំ សង្កាត់។**

រៀបរៀង និងបោះពុម្ពផ្សាយដោយ
គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

ទីស្តីការ គ.ជ.ប វិថីរដ្ឋសភា សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ
ទូរសព្ទ (Tel) : (+855) 23 235 271
អ៊ីម៉ែល (Email): info@nec.gov.kh
Website: www.nec.gov.kh, voterlist.nec.gov.kh
Facebook/Youtube: National Election Committee
APP: NEC KH, CamNEC News